GC LiFE

# GC គ្រុបឃែរ



## តើអ្វីទៅជា GC គ្រុបឃែរ ?

GC គ្រុបឃែរ គឺជាគម្រោងធានារ៉ាប់រងរយៈពេល១ឆ្នាំ ដែលត្រូវបានរចនាឡើងយ៉ាងពិសេសសម្រាប់បុគ្គលិករបស់អ្នក និងសមាជិកគ្រួសាររបស់ពួកគាត់។គម្រោងនេះផ្តល់នូវការការពារ 24/7 សម្រាប់ពួកគាត់មិនថាពួកគាត់នៅទីកន្លែងណាក៏ដោយ។

## តើអ្នកណាសាកសមនឹង GC គ្រុបឃែរ ?

បុគ្គលិករបស់អ្នក និងស្វាមី/ភរិយា/បុត្រធីតារបស់ពួកគាត់។

## ហេតុអ្វីជ្រើសរើស GC គ្រុបឃែរ ?

GC គ្រុបឃែរ គឺជាគម្រោងធានារ៉ាប់រងដែលមានតម្លៃសមរម្យ និងផ្តល់ការការពារខ្ពស់ ព្រមទាំងមានជម្រើសជាច្រើនសម្រាប់ជ្រើសរើសជាមួយនឹងសំណងមរណភាព និងពិការភាពដោយគ្រោះថ្នាក់ជាយថាហេតុរហូតដល់ ៦ដងនៃទឹកប្រាក់ត្រូវបានធានា។ លើសពីនេះទៅទៀត លោកអ្នកក៏អាចជាវនូវ អត្ថប្រយោជន៍បន្ថែមមេឌីឃែរ ភ្ជាប់ជាមួយ GC គ្រុបឃែរ ដើម្បីផ្តល់នូវអត្ថប្រយោជន៍បន្ថែមដល់បុគ្គលិករបស់លោកអ្នក ដូចជាប្រាក់ឧបត្ថម្ភសម្រាកពេទ្យ អត្ថប្រយោជន៍សម្រាប់ការវះកាត់ និងអត្ថប្រយោជន៍សម្រាប់ជំងឺគ្រុនឈាម/គ្រុនចាញ់។



## លក្ខណៈនៃផលិតផល

| | |
|---|---|
| ចំនួនសមាជិកដែលត្រូវបានធានា | ចាប់ពី 5នាក់ឡើង |
| អាយុសមាជិកដែលត្រូវបានធានា / ស្វាមីឬភរិយារបស់គាត់ | 18 – 64ឆ្នាំ |
| អាយុបុត្រធីតារបស់សមាជិកដែលត្រូវបានធានា | 1 – 17ឆ្នាំ |
| រយៈពេលធានារ៉ាប់រង | 1ឆ្នាំ |
| ទឹកប្រាក់ត្រូវបានធានា | ចាប់ពី $5,000ឡើង |

## អត្ថប្រយោជន៍ធានារ៉ាប់រង

GC គ្រុបឃែរ មានគម្រោងអត្ថប្រយោជន៍ចំនួន៦ សម្រាប់ជ្រើសរើសដូចបានបង្ហាញក្នុងតារាងខាងក្រោម។ ឧទាហរណ៍៖ ប្រសិនបើអ្នកជ្រើសរើសនូវគម្រោង 3 សម្រាប់សមាជិកដែលត្រូវបានធានា នោះសំណងមរណភាព ឬពិការភាពទាំងស្រុងនិងជាអចិន្ត្រៃយ៍ ដែលមិនមែនបណ្តាលមកពីគ្រោះថ្នាក់ជាយថាហេតុគឺស្មើនឹង 100%នៃទឹកប្រាក់ត្រូវបានធានា ហើយសំណងមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយគ្រោះថ្នាក់ជាយថាហេតុគឺស្មើនឹង 300% នៃទឹកប្រាក់ត្រូវបានធានា។

| គម្រោង | មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដែលមិនមែនបណ្តាលមកពីគ្រោះថ្នាក់ជាយថាហេតុ | មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដោយគ្រោះថ្នាក់ជាយថាហេតុ |
|---|---|---|
| 1. | 100% នៃទឹកប្រាក់ត្រូវបានធានា | 100% នៃទឹកប្រាក់ត្រូវបានធានា |
| 2. | 100% នៃទឹកប្រាក់ត្រូវបានធានា | 200% នៃទឹកប្រាក់ត្រូវបានធានា |
| 3. | 100% នៃទឹកប្រាក់ត្រូវបានធានា | 300% នៃទឹកប្រាក់ត្រូវបានធានា |
| 4. | 100% នៃទឹកប្រាក់ត្រូវបានធានា | 400% នៃទឹកប្រាក់ត្រូវបានធានា |
| 5. | 100% នៃទឹកប្រាក់ត្រូវបានធានា | 500% នៃទឹកប្រាក់ត្រូវបានធានា |
| 6. | 100% នៃទឹកប្រាក់ត្រូវបានធានា | 600% នៃទឹកប្រាក់ត្រូវបានធានា |

## ទទួលបានអត្ថប្រយោជន៍កាន់តែច្រើនដោយបន្ថែមទៀត អត្ថប្រយោជន៍បន្ថែមគ្រប់មេឌីឃែរ៖



### ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ

សម្រាកព្យាបាលនៅមន្ទីរពេទ្យដោយ
(ក) ជំងឺ ឬគ្រោះថ្នាក់ជាយថាហេតុ ឬ
(ខ) គ្រោះថ្នាក់ជាយថាហេតុ



### អត្ថប្រយោជន៍សម្រាប់ការវះកាត់

ធ្វើការវះកាត់ដោយ
(ក) ជំងឺ ឬគ្រោះថ្នាក់ជាយថាហេតុ ឬ
(ខ) គ្រោះថ្នាក់ជាយថាហេតុ



### អត្ថប្រយោជន៍សម្រាប់ជំងឺគ្រុនឈាម/គ្រុនចាញ់

ធ្វើរោគវិនិច្ឆ័យរកឃើញជំងឺគ្រុនឈាម/គ្រុនចាញ់ សម្រាកព្យាបាលនៅមន្ទីរពេទ្យដោយជំងឺគ្រុនឈាម/គ្រុនចាញ់ ឬទទួលមរណភាពដោយជំងឺគ្រុនឈាម/គ្រុនចាញ់

## ករណីមិនធានា

**១. មរណភាព**

មិនមានសំណងមរណភាពនឹងត្រូវផ្តល់ជូននោះទេ ប្រសិនបើមរណភាពរបស់សមាជិកដែលត្រូវបានធានា ត្រូវបានបង្កឡើងដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬដោយផ្នែក ដោយសារព្រឹត្តិការណ៍ណាមួយដូចខាងក្រោម៖
(១) ការធ្វើអត្តឃាតក្នុងរយៈពេល ២ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមសុពលភាពនៃបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយ។
(២) ការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។
(៣) វីរុសហ៊ីវ (HIV) និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ (HIV) ដែលរួមមានទាំងជំងឺអេដស៍ និង/ឬការបំលែង ការវិវត្តន៍ ឬការប្រែប្រួលនៃមេរោគអេដស៍។
(៤) ការប្រើប្រាស់ថ្នាំញៀន ឬថ្នាំភ្លោចអារម្មណ៍ ឬការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬរោគសញ្ញាផ្សេងៗដូចដែលបានកំណត់ដោយច្បាប់ដែលបានចូលជាធរមាន។

**២. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**

ក្រុមហ៊ុនមិនធានាលើការបាត់បង់ ឬពិការភាពដែលបណ្ដាលមកពីព្រឹត្តិការណ៍ដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬ ដោយផ្នែក ដោយសារព្រឹត្តិការណ៍ណាមួយដូចខាងក្រោម៖

(១) ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។

(២) ការឆ្លងវីរុសហ៊ីវ (HIV) រោគសញ្ញានៃជំងឺអេដស៍ ឬជំងឺដែលទាក់ទងនឹងជំងឺអេដស៍។

(៣) សង្គ្រាម (មិនថាបានប្រកាស ឬមិនបានប្រកាស) សកម្មភាពលុកលុយរបស់សត្រូវបរទេស សង្គ្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ការធ្វើកូដកម្ម ការកើនឡើងប្រជាប្រិយភាពប្រឆាំងនឹងរដ្ឋាភិបាលនិងអំពើភេរវកម្ម។

(៤) ខណៈពេលដែលសមាជិកដែលត្រូវបានធានាប្រព្រឹត្តបទឧក្រិដ្ឋ ឬខណៈពេលដែលសមាជិកដែលត្រូវបានធានាកំពុងត្រូវបានចាប់ខ្លួន ឬត្រូវរងការចាប់ខ្លួន ឬកំពុងរត់គេចពីការចាប់ខ្លួន។

(៥) ការធ្វើដំណើរចូល ការចាកចេញ ការប្រតិបត្តិការ ការផ្ដល់សេវា ឬត្រូវបានបញ្ជូនដោយយាន ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីសមាជិកដែលត្រូវបានធានាគឺជាអ្នកដំណើរបង់ប្រាក់ធម្មតា ឬអ្នកបម្រើការលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ពាណិជ្ជមួយ ដែលធ្វើការជាប្រចាំ និងទៀងទាត់តាមកាលវិភាគ និងគន្លងធ្វើដំណើរផ្លូវអាកាសដែលបានកំណត់របស់ក្រុមហ៊ុន។

(៦) ខណៈពេលដែលសមាជិកដែលត្រូវបានធានាបំពេញកាតព្វកិច្ចជាយោធា ប៉ូលីស ឬជាអ្នកស្ម័គ្រចិត្តចូលរួមក្នុងសង្គ្រាម ឬការបង្រ្កាបឧក្រិដ្ឋកម្ម។

(៧) ស្ថានភាពដែលមានពីមុនស្រាប់ មុនកាលបរិច្ឆេទចាប់ផ្ដើមសុពលភាពនៃបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។ ស្ថានភាពដែលមានពីមុនស្រាប់ មានន័យថាជាជំងឺដែលសមាជិកដែលត្រូវបានធានាបានដឹងច្បាស់ លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុន និងទទួលយកដោយក្រុមហ៊ុន។ សមាជិកដែលត្រូវបានធានាអាចត្រូវបានចាត់ទុកថាបានដឹងច្បាស់អំពីស្ថានភាពដែលមានពីមុនស្រាប់ ប្រសិនបើមានស្ថានភាពណាមួយដូចបានចែងខាងក្រោម៖

ក) សមាជិកដែលត្រូវបានធានាបានទទួល ឬកំពុងទទួលការព្យាបាល

ខ) យោបល់វេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រត្រូវបានណែនាំ

គ) មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ ឬ

ឃ) វត្តមាននៃស្ថានភាពនោះអាចមើលឃើញដោយបុគ្គលធម្មតាក្នុងកាលៈទេសៈណាមួយ។

(៨) សមាជិកដែលត្រូវបានធានាស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយ លើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។

(៩) ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីព។

**៣. មរណភាព និងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដោយគ្រោះថ្នាក់ជាយថាហេតុ**

(១) ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។

(២) ការឆ្លងវីរុសហ៊ីវ (HIV) រោគសញ្ញានៃជំងឺអេដស៍ ឬជំងឺដែលទាក់ទងនឹងជំងឺអេដស៍។

(៣) សង្គ្រាម (មិនថាបានប្រកាស ឬមិនបានប្រកាស) សកម្មភាពលុកលុយរបស់សត្រូវបរទេស សង្គ្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ការធ្វើកូដកម្ម ការកើនឡើងប្រជាប្រិយភាពប្រឆាំងនឹងរដ្ឋាភិបាល និងអំពើភេរវកម្ម។

(៤) ខណៈពេលដែលសមាជិកដែលត្រូវបានធានាប្រព្រឹត្តបទឧក្រិដ្ឋ ឬខណៈពេលដែលសមាជិកដែលត្រូវបានធានាកំពុងត្រូវបានចាប់ខ្លួន ឬត្រូវរងការចាប់ខ្លួន ឬកំពុងរត់គេចពីការចាប់ខ្លួន។

(៥) ការធ្វើដំណើរចូល ការចាកចេញ ការប្រតិបត្តិការ ការផ្ដល់សេវា ឬត្រូវបានបញ្ជូនដោយយាន ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីសមាជិកដែលត្រូវបានធានា គឺជាអ្នកដំណើរបង់ប្រាក់ធម្មតា ឬអ្នកបម្រើការលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ពាណិជ្ជមួយដែលធ្វើការ ហោះហើរជាប្រចាំ និងទៀងទាត់តាមកាលវិភាគហោះហើរ និងគន្លងធ្វើដំណើរផ្លូវអាកាសដែលបានកំណត់របស់ក្រុមហ៊ុន។

(៦) ខណៈពេលដែលសមាជិកដែលត្រូវបានធានាបំពេញកាតព្វកិច្ចជាយោធា ប៉ូលីស ឬជាអ្នកស្ម័គ្រចិត្ត ចូលរួមក្នុងសង្គ្រាម ឬការបង្រ្កាបឧក្រិដ្ឋកម្ម។

(៧) សមាជិកដែលត្រូវបានធានាបានដឹងអំពីបញ្ហារាងកាយថាមានជំងឺ ឬរបួសមុនពេលចាប់ផ្ដើម កិច្ចសន្យាធានារ៉ាប់រង ប៉ុន្តែសមាជិកដែលត្រូវបានធានាមិនបានជូនដំណឹងដល់ក្រុមហ៊ុនឡើយ។

(៨) សមាជិកដែលត្រូវបានធានាស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយ លើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណចុះបញ្ជីត្រឹមត្រូវ។

(៩) ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីព។

(១០) ការមានគភ៌ ការសម្រាលកូន ការរលូតកូន ឬផលវិបាកណាមួយកើតចេញពីកត្តាទាំងអស់នេះ។

ចំណាំ៖ ខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិត សូមអាន ខ និងលក្ខខណ្ឌធានារ៉ាប់រង។ ក្នុងករណីដែលកើតមានភាពមិនស៊ីចង្វាក់គ្នា ត្រូវយក ខ និងលក្ខខណ្ឌធានារ៉ាប់រងជាគោល។

## ទំនាក់ទំនងមកកាន់យើងខ្ញុំ


023-989-218 / 098-989-218

service@gc-life.com.kh www.gc-life.com.kh

អគារ C ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ